# នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 24-Jun-2016, 13:37
CMS/CFO: Sann Rada

សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស

សារណារបស់ Ido Rosenzweig ដែលមិនមែនជាភាគី ស្តីពីបញ្ហាចោទថាតើ តាមច្បាប់ទម្លាប់អន្តរជាតិ ដែលចូលជាធរមាននៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ការវាយប្រហាររបស់រដ្ឋ ឬអង្គការមកលើសមាជិកនៃកងកម្លាំងប្រដាប់អាវុធផ្ទាល់ខ្លួន អាច ឬក៏មិនអាចជាការវាយប្រហារដែលសំដៅលើ“ប្រជាជនស៊ីវិល” តាមគោលបំណងនៃមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)។

## សង្ខេប

សារណានេះធ្វើជូនយោងតាមសេចក្ដីជូនដំណឹងជាសាធារណៈចេញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៦ ដែលអញ្ជើញឱ្យមានការដាក់សារណាពីអ្នកដែលមិនមែនជាភាគី យោងតាមវិធានផ្ទៃក្នុង ៣៣ របស់ អ.វ.ត.ក ស្ដីបញ្ហាចោទសួរ "ថាតើតាមច្បាប់ទម្លាប់អន្តរជាតិដែលចូលជាធរមាននៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះ ការវាយប្រហាររបស់រដ្ឋ ឬ អង្គការមកលើសមាជិកនៃកងកម្លាំងប្រដាប់អាវុធ*ផ្ទាល់ខ្លួន* អាច ឬក៏មិនអាចជាការវាយប្រហារដែលសំដៅលើប្រជាជនស៊ីវិល បើយោងតាមគោលបំណងនៃមាត្រា ៥ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក"[1]។

## ជំនាញរបស់អ្នកដែលមិនមែនជាភាគី

Ido Rosenzeig គឺជានាយកផ្នែកស្រាវជ្រាវ(ភេរវកម្ម និងបច្ចាមិត្ត) នៅមជ្ឈមណ្ឌល Minerva សម្រាប់នីតិរដ្ឋនៅក្នុងលក្ខខណ្ឌធ្ងន់ធ្ងរ នៅមហាវិទ្យាល័យនីតិសាស្ត្រ និង ដេប៉ាតឺម៉ង់ភូមិសាស្ត្រ និងសិក្សាបរិស្ថាន សាកលវិទ្យាល័យ Haifa ប្រទេសអ៊ីស្រាអែល។ គាត់ក៏ជាប្រធាន និងសហស្ថាបនិក ALMA (សមាគមលើកកម្ពស់ច្បាប់មនុស្សធម៌អន្តរជាតិ) ជាអង្គការក្រៅរដ្ឋាភិបាលមិនរកប្រាក់ចំណេញ និងជាបេក្ខជនបណ្ឌិតនៅសាកលវិទ្យាល័យ Hebrew University of Jerusalem ប្រទេសអ៊ីស្រាអែល។ គាត់បាននិងកំពុងធ្វើការក្នុងវិស័យច្បាប់អន្តរជាតិរយៈពេលជាង ១០ ឆ្នាំ ហើយមានបរិញ្ញាបត្រនីតិសាស្ត្រពីសាកលវិទ្យាល័យ តេល អាវី ប្រទេសអ៊ីស្រាអែល និងអនុបណ្ឌិតនីតិសាស្ត្រមកពីសាកលវិទ្យាល័យតេល អាវី ប្រទេសអ៊ីស្រាអែល និងសាកលវិទ្យាល័យ Northwestern នៅឈីកាហ្គូ សហរដ្ឋអាមេរិក។ ការយល់ឃើញដែលបានបង្ហាញនៅក្នុងសារណានេះគឺជាការយល់ឃើញរបស់គាត់ផ្ទាល់ខ្លួនឯង។

[1] http://www.eccc.gov.kh/sites/default/files/documents/courtdoc/2016-04-20%2017:53/D191_EN.PDF.

## សេចក្តីផ្តើម

ស្របតាមការអញ្ជើញរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិនៃ អ.វ.ត.ក សារណាមិនមែនជាភាគីនេះនឹងមិនពណ៌នាលម្អិតអំពីការវិវត្តនៃ"ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"នៅក្រោមច្បាប់អន្តរជាតិឡើយ ហើយសារណានេះនឹងផ្តោតលើនិយមន័យនៃពាក្យថា"ប្រជាជនស៊ីវិល" តាមមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ជាពិសេសផ្តោតលើបញ្ហាថាតើនិយមន័យនេះអាចរាប់បញ្ចូលទាំងសមាជិកនៃកងកម្លាំងប្រដាប់អាវុធផ្ទាល់ខ្លួនរបស់រដ្ឋ ឬអង្គការដែរឬអត់។

ដើម្បីដោះស្រាយបញ្ហាចោទនេះ យើងត្រូវតែផ្តោតលើបញ្ហាចំនួនបី៖

(១) តើ"ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"អាចប្រព្រឹត្តមកលើយុទ្ធជនដែរឬទេ?

(២) តើ"ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"អាចប្រព្រឹត្តមកលើយុទ្ធជនរបស់ខ្លួនឯងដែរឬទេ?

(៣) តើ"ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"បែបនេះមានអត្ថិភាពនៅក្នុងច្បាប់ទម្លាប់អន្តរជាតិនៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដែរឬទេ?

### (១) <u>**តើ"ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"អាចប្រព្រឹត្តមកលើយុទ្ធជនដែរឬទេ?**</u>

អត្ថន័យនៃពាក្យថា"ប្រជាជនស៊ីវិល"នៅក្នុងបរិបទ"ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" ត្រូវបានដោះស្រាយដោយសាលាក្តីអន្តរជាតិមួយចំនួនរួចហើយ។ យុត្តិសាស្ត្ររបស់តុលាការ ICTY និង ICTR ពឹងផ្អែកការយល់ឃើញរបស់ខ្លួនលើនិយមន័យទូទៅនៃពាក្យថា"ប្រជាជនស៊ីវិល" តាមច្បាប់មនុស្សធម៌អន្តរជាតិ ដោយសម្រេចថា ជនដែលមិនអាចទទួលរងការវាយប្រហារដោយផ្ទាល់ គឺ"**ជនដែលមិនចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពអរិភាព រួមមានសមាជិកនៃកងកម្លាំងប្រដាប់អាវុធដែលបានទម្លាក់អាវុធ និងជនដែលស្ថិតក្នុងស្ថានភាពបាត់បង់សមត្ថភាពប្រយុទ្ធ ដោយសារជំងឺ របួស ការឃុំខ្លួន និងមូលហេតុណាផ្សេងទៀត**"[2]។

ក្រោយមក សញ្ញាណអំពីប្រជាជន"ស៊ីវិល"នៅក្នុងបរិបទ"ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"ត្រូវបានបញ្ជាក់នៅក្នុងរឿងក្តី *Kayishema* និង *Ruzindana* ដែលអង្គជំនុំជម្រះសាលាដំបូង បានសម្រេចថា៖

> ជាប្រពៃណី និយមន័យច្បាប់អំពី "ជនស៊ីវិល" ឬ "ប្រជាជនស៊ីវិល" បានពិភាក្សានៅក្នុងបរិបទជម្លោះប្រដាប់អាវុធ។ ប៉ុន្តែ តាមលក្ខន្តិកៈ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អាចប្រព្រឹត្តឡើងនៅក្នុង

[2] Akayesu (អង្គជំនុំជម្រះសាលាដំបូង) ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៥៨២។

ឬនៅក្រៅបរិបទជម្លោះប្រដាប់អាវុធ។ ហេតុនេះ ពាក្យថា ជនស៊ីវិល ត្រូវតែយល់នៅក្នុងបរិបទសង្គ្រាម និងសន្តិភាព។ អង្គជំនុំជម្រះសាលាដំបូង យល់ឃើញថា និយមន័យទូលំទូលាយអំពីពាក្យថា ជនស៊ីវិល អាចយកមកអនុវត្តបាន ហើយនៅក្នុងបរិបទស្ថានភាពក្រុង Kibuye ដែលមិនមានជម្លោះប្រដាប់អាវុធ និយមន័យនេះរាប់បញ្ចូលទាំងជនទាំងអស់ក្រៅពីជនដែលមានករណីយកិច្ចថែរក្សាសណ្តាប់ធ្នាប់សាធារណៈ និងមានមធ្យោបាយសមស្របច្បាប់ដើម្បីប្រើប្រាស់កម្លាំង[3]។

និយមន័យដដែលនេះអាចរកឃើញមាននៅក្នុងយុត្តិសាស្ត្ររបស់តុលាការICTY នៅក្នុងរឿងក្តី *Blagojevic* និង *Jokic* ៖

“ពាក្យថា “ជនស៊ីវិល”សំដៅលើជនដែលមិនចូលរួមនៅក្នុងសកម្មភាពអរិភាព រួមមានសមាជិកនៃកងម្លាំងប្រដាប់អាវុធដែលបានទម្លាក់អាវុធ និងជនដែលស្ថិតក្នុងស្ថានភាពបាត់បង់សមត្ថភាពប្រយុទ្ធ ដោយសារជំងឺ របួស ការឃុំខ្លួន និងមូលហេតុណាផ្សេងទៀត ” ។ វាជាគោលការណ៍មួយនៃច្បាប់ទម្លាប់អន្តរជាតិដែលថា ជនទាំងនេះត្រូវការពារនៅក្នុងជម្លោះប្រដាប់អាវុធ” [4]។

ហេតុនេះ ហាក់ដូចជាច្បាស់ថា សញ្ញាណអំពី“ជនស៊ីវិល”គឺពឹងផ្អែកលើនិយមន័យដែលពាក់ព័ន្ធនេះនៅក្រោមច្បាប់មនុស្សធម៌អន្តរជាតិ ប៉ុន្តែក៏ច្បាស់ផងដែរថា នៅក្នុងបរិបទ“ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ” សញ្ញាណនេះគួរតែបកស្រាយឲ្យបានទូលំទូលាយ។ ឧទាហរណ៍ យុទ្ធជនដែលបាត់បង់សមត្ថភាពប្រយុទ្ធរក្សាចំណាត់ថ្នាក់របស់ខ្លួនជាយុទ្ធជននៅក្រោមច្បាប់មនុស្សធម៌អន្តរជាតិ ប៉ុន្តែនៅក្នុងបរិបទ“ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ” យុទ្ធជនបែបនេះត្រូវចាត់ទុកថាជាផ្នែកមួយនៃប្រជាជនស៊ីវិល។ ចំណុចនេះកាន់តែស៊ីគ្នាថែមទៀតនៅពេលដែលពិចារណាគោលបំណងនៃការហាមឃាត់ប្រឆាំង“ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ”ដើម្បីការពារតម្លៃមនុស្សជាតិជាមូលដ្ឋាន ដោយហាមឃាត់អំពើឃោរឃៅដែលសំដៅលើសេចក្តីថ្លៃថ្នូរមនុស្សជាតិ[5]។

ហេតុនេះ ហាក់ដូចជាថា ស្របតាមយុត្តិសាស្ត្ររបស់តុលាការ ICTY និង ICTR និយមន័យអំពីពាក្យថា “ជនស៊ីវិល”មានន័យទូលំទូលាយជាងនិយមន័យអំពីជនស៊ីវិលនៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិ និងជា

---

[3] រឿងក្តី *Kayishema និង Ruzindana* (អង្គជំនុំជម្រះសាលាដំបូង) ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៩ កថាខណ្ឌ ១២៧។

[4] រឿងក្តី *Blagojevic និង Jokic* (អង្គជំនុំជម្រះសាលាដំបូង) ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ កថាខណ្ឌ ៥៤៤។

[5] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Kupreskic និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-95-16 (អង្គជំនុំជម្រះសាលាដំបូង) ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០០ កថាខណ្ឌ ៥៤៧។

ពិសេសមាត្រា ៥០ នៃពិធីសារបន្ថែម I។ ប៉ុន្តែ សំខាន់ត្រូវកត់សម្គាល់ថា ធាតុផ្សំពាក់ព័ន្ធចំនួនពីរ បានកើតចេញពីយុត្តិសាស្ត្រនេះ។

១. និយមន័យអំពីពាក្យថា ប្រជាជនស៊ីវិល នៅក្រោម"ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" មិនរាប់បញ្ចូលយុទ្ធជន និង**ជនស៊ីវិល**ដែលចូលរួមផ្ទាល់នៅក្នុងសកម្មភាពអរិភាពឡើយ។ និយមន័យនេះផ្ទុយពីច្បាប់មនុស្សធម៌អន្តរជាតិ ដែលភាពខុសគ្នារវាងជនស៊ីវិល និងយុទ្ធជន គឺជាចំណុចសំខាន់ ហើយមានលទ្ធផលសំខាន់ៗមួយចំនួន ដែលតាមទស្សនៈអំពីយុទ្ធជន រួមមានឯកសិទ្ធិ ដូចជា "អភ័យឯកសិទ្ធិយុទ្ធជន"។ ហេតុនេះ វិសាលភាពនៃពាក្យថា ជនស៊ីវិល នៅក្រោម"ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" **មិនរាប់បញ្ចូលប្រជាជនស៊ីវិលទាំងអស់ឡើយ** (ពីព្រោះថា ពាក្យនេះមិនរាប់បញ្ចូលជនស៊ីវិលដែលចូលរួមសកម្មភាពអរិភាពឡើយ)។

២. និយមន័យនេះអំពីពាក្យថា "ជនស៊ីវិល" រាប់បញ្ចូលទាំងយុទ្ធជនដែលបាត់បង់សមត្ថភាពប្រយុទ្ធ ឬជនដែលបានទម្លាប់អាវុធ។ តាមច្បាប់មនុស្សធម៌អន្តរជាតិ យុទ្ធជនបែបនេះ មិនបាត់បង់ឋានៈជាយុទ្ធជន និងឯកសិទ្ធិរបស់ខ្លួនឡើយ ប៉ុន្តែ យោងតាមយុត្តិសាស្ត្រនេះ ពួកគេធ្លាក់ចូលក្នុងប្រភេទក្រុម"ជនស៊ីវិល"តាមគោលបំណងនៃ"ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"។

ហេតុនេះ និយមន័យអំពី "ជនស៊ីវិល"នៅក្នុងបរិបទ"ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" ពឹងផ្អែកលើមុខងាររបស់ជននោះ គឺ តួនាទីមុខងាររបស់គាត់នៅក្នុងអំឡុងពេលជម្លោះប្រដាប់អាវុធ។ ជនដែលមិនចូលរួមទាល់តែសោះនៅក្នុងជម្លោះ ត្រូវចាត់ទុកថាជាផ្នែកមួយនៃ"ប្រជាជនស៊ីវិល"។ នេះគឺផ្ទុយស្រឡះពីនិយមន័យអំពីយុទ្ធជន នៅក្រោមច្បាប់មនុស្សធម៌អន្តរជាតិ។ ដូច្នេះ ចំពោះសំណួរទី១ ដែលថា"តើ "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"អាចប្រព្រឹត្តមកលើយុទ្ធជនដែរឬទេ?" ចម្លើយគឺថា អាច។ នៅក្នុងស្ថានភាពមួយចំនួន យុទ្ធជនអាចត្រូវចាត់ទុកថាជាជនស៊ីវិល តាមគោលបំណងនៃ "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"។

## (២) <u>តើ "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"អាចប្រព្រឹត្តមកលើយុទ្ធជនរបស់ខ្លួនឯងដែរឬទេ?</u>

វិធាននៃច្បាប់មនុស្សធម៌អន្តរជាតិ ដែលធ្វើនិយតកម្មលើទង្វើមកលើយុទ្ធជនផ្ទាល់ខ្លួនរបស់រដ្ឋ អាចមានកម្រិតណាស់។ បទប្បញ្ញត្តិភាគច្រើនលើសលុបនៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិ ដែលបានរៀបចំជាក្រមនៅក្នុងបទបញ្ជាទីក្រុងឡាអេ ឆ្នាំ ១៩០៧ អនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ និងពិធីសារបន្ថែមឆ្នាំ ១៩៧៧ ព្រមទាំងតាមទំនៀមទម្លាប់នៃច្បាប់មនុស្សធម៌អន្តរជាតិ គឺពាក់ព័ន្ធនឹងការប្រព្រឹត្តិមកលើយុទ្ធជនបច្ចាមិត្ត និងជនស៊ីវិលបច្ចាមិត្ត។ ដោយសារមូលហេតុនេះហើយ ទើបមានសំណួរទី ២។ គោលបំណងនៃ

“ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ”គឺដើម្បីបំពេញចន្លោះប្រហោងនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ពោលគឺការរំលោភបំពានដែលមិនមានចែងនៅក្នុង“ឧក្រិដ្ឋកម្មសង្គ្រាម”។

មូលហេតុដែល “ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ” ផ្ដោតលើអំពើដែលបានប្រព្រឹត្តឡើងមកលើជនស៊ីវិល គឺពឹងផ្អែកលើសញ្ញាណដែលថា អំពើឃោរឃៅដូចគ្នានេះដែលប្រព្រឹត្តមកលើយុទ្ធជនបច្ចាមិត្ត គឺមានចែងនៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិ ហើយដូចដែល Cassese បញ្ជាក់ដែរ គឺថា៖

> “មូលហេតុដែលមាត្រា ៦ (គ) មានវិសាលភាពកំណត់បែបនេះ គឺថា យុទ្ធជនខ្មាំង ត្រូវបានការពាររួចហើយតាមប្រពៃណីនៃច្បាប់សឹកសង្គ្រាម **ខណៈដែលគេចាត់ទុកថាមិនទំនងជាថាបច្ចាមិត្តអាចប្រព្រឹត្តអំពើឃោរឃៅមកលើទាហានខ្លួនឯង ឬមកលើទាហានរបស់ប្រទេសសម្ព័ន្ធមិត្តឡើយ**”[6]។(គូសបញ្ជាក់បន្ថែម)

Cassese ក៏សម្រេចថា អំពើឃោរឃៅមកលើកងកម្លាំងប្រដាប់អាវុធខ្លួនឯង គួរតែចាត់ទុកថាជាអំពើធ្វើឡើងក្នុងស្រុក ហេតុនេះ មិនមានទស្សនាទានអំពី“ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ”មកលើយុទ្ធជនរបស់ខ្លួនឯង តាមច្បាប់អន្តរជាតិឡើយ។ ប៉ុន្តែ ប្រសិនបើយើងទទួលយកសញ្ញាណជាមូលដ្ឋានដែលថា “ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ”មានបំណងបញ្ចូលអំពើឃោរឃៅយ៉ាងរង្គាលមកលើជនស៊ីវិល ហើយការយល់ឃើញថា “ឧក្រិដ្ឋកម្មសង្គ្រាម”មិនបញ្ចូលអំពើឃោរឃៅបែបនេះឡើយនៅពេលដែលប្រព្រឹត្តមកលើយុទ្ធជនរបស់ខ្លួនឯងនោះ គឺចាំបាច់ត្រូវពិនិត្យថាតើ “ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ”មានបំណង និងអាចបញ្ចូលអំពើឃោរឃៅពាក់ព័ន្ធនានាមកលើយុទ្ធជនរបស់ខ្លួនឯងដែរឬអត់។

តាមការយល់ឃើញរបស់ខ្ញុំ មិនមានយុត្តិសាស្ត្រដែលប្រើប្រាស់ក្របខណ្ឌ“ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ” ដើម្បីស៊ើបអង្កេត ឬចោទប្រកាន់អំពីការប្រព្រឹត្តិឧក្រិដ្ឋកម្មមកយុទ្ធជនរបស់ខ្លួនឯងឡើយ។ ប៉ុន្តែ ការមិនមានការអនុវត្តបែបនេះមិនគួរនាំឲ្យមានសេចក្ដីសន្និដ្ឋានជាស្វ័យប្រវត្តិថា ក្រុមមនុស្សប្រភេទនេះត្រូវបានដកចេញពីក្របខណ្ឌវិធានការការពារបានឡើយ។ ផ្ទុយមកវិញ ក្រុមមនុស្សប្រភេទនេះត្រូវបញ្ចូលនៅក្នុងក្របខណ្ឌវិធានការការពារ។

គោលជំហរដែលថា ការវាយប្រហារមកលើយុទ្ធជនរបស់ខ្លួនឯង អាចស្ថិតនៅក្នុងវិសាលភាពនៃ“ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ” អាចពឹងផ្អែកលើសញ្ញាណចំនួចពីរ៖

---

[6] Casses, A, ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ៖ មតិយោបល់ស្ដីពីចំណុចបញ្ហាខ្លះ នៅក្នុងឯកសារ Casses, A ផ្នែកមនុស្សនៃច្បាប់អន្តរជាតិ សារណាសម្រិតសម្រាំង សារព័ត៌មានសាកលវិទ្យាល័យអុកស្វើដ ឆ្នាំ ២០០៨ ទំព័រ ៤៦៦។

១. ផ្អែកលើសីលធម៌- តាមសីលធម៌ ហាក់ដូចជាមិនអាចគិតថា ការប្រព្រឹត្តិអំពើឃោរឃៅបែបនោះ នឹងប្រព្រឹត្តមកលើយុទ្ធជនបច្ចាមិត្ត ជនស៊ីវិលបច្ចាមិត្ត និងជនស៊ីវិលរបស់ភាគីខ្លួនឯង ប៉ុន្តែមិនមែន មកលើយុទ្ធជនរបស់ខ្លួនឯងឡើយ។ បើមិនអញ្ចឹងទេ មានលទ្ធផលថា បទបញ្ជាឱ្យ "ហៅទាហាន ជីហ្វីសទាំងអស់នៅក្នុងកងកម្លាំងរបស់យើង" ឬក៏បទបញ្ជាឱ្យ"រំលោភ និងធ្វើទារុណកម្មទាហាន នារីជីហ្វីសទាំងអស់នៅក្នុងកងកម្លាំងរបស់យើង" នឹងមិនមាននៅក្នុងក្របខណ្ឌ"ឧក្រិដ្ឋកម្មប្រឆាំង មនុស្សជាតិ"ឡើយ។

២. ផ្អែកលើអង្គសេចក្តី- ដូចបានបង្ហាញមុនរួចហើយ និយមន័យអំពីជនស៊ីវិល នៅក្រោម"ឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិ" រាប់បញ្ចូលទាំងជនស៊ីវិល ទាំងយុទ្ធជនបច្ចាមិត្តមួយចំនួន ហើយមិនរាប់ បញ្ចូលយុទ្ធជនបច្ចាមិត្ត និងជនស៊ីវិលមួយចំនួន។ លក្ខខណ្ឌសម្រាប់ធ្វើចំណាត់ថ្នាក់នេះ ពឹងផ្អែក លើអង្គសេចក្តី មិនមែនពឹងផ្អែកលើការធ្វើចំណាត់ថ្នាក់ផ្លូវការឡើយ។ នៅពេលដែលយើងអនុវត្ត លក្ខខណ្ឌមុខងារនេះចំពោះយុទ្ធជនផ្ទាល់ខ្លួនរបស់ភាគីណាមួយ យើងអាចមើលឃើញថា "ឧក្រិដ្ឋ កម្មប្រឆាំងមនុស្សជាតិ"អាចប្រព្រឹត្តឡើងមកលើយុទ្ធជនបែបនោះ។ បន្ថែមពីលើនេះទៀត ចំពោះ យុទ្ធជនរបស់ខ្លួនឯង លក្ខខណ្ឌមុខងារនេះត្រូវតែពិនិត្យឱ្យបានកាន់តែទូលំទូលាយ។ ពួកគេត្រូវ ចាត់ទុកថាជាជនស៊ីវិល មិនមែនតែនៅពេលដែលពួកគេបាត់បង់សមត្ថភាពប្រយុទ្ធឡើយ ប៉ុន្តែក៏ នៅពេលដែលពួកគេកំពុងទទួលរងអំពើឃោរឃៅបែបនោះផងដែរ-- នៅពេលដែលពួកគេជា កម្មវត្ថុនៃការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធ គឺ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យ ទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភផ្លូវភេទ ឬការ ធ្វើទុក្ខបុកម្នេញ ខណៈដែលពួកគេលែងបំពេញតួនាទីមុខងារជាយុទ្ធជនទៀតហើយ។ តាម លក្ខខណ្ឌទាំងនេះ ពួកគេមិនអាចត្រូវចាត់ទុកថាជាយុទ្ធជនរបស់ភាគីខ្លួនឯងឡើយ ហើយពួកគេ ត្រូវចាត់ទុកថាជាជនស៊ីវិល នៅក្នុងក្របខណ្ឌ"ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"។

(៣) **តើការហាមឃាត់នេះឆ្លុះបញ្ចាំងពីច្បាប់ទម្លាប់អន្តរជាតិនៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដែរ ឬទេ?**



*សារណាមិនមែនជាភាគីស្តីពីនីត្យានុកូលភាពនៃការដាក់គោលដៅលើយោធាខ្លួនឯង*

ទស្សនាទានអំពី“ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ”មានតាំងពីរាប់ទស្សវត្សរ៍មុនម្ល៉េះ បើមិនរាប់សតវត្សរ៍ទេ។ អត្ថន័យបច្ចុប្បន្ននៃទស្សនាទាននេះ មានតាំងពីឆ្នាំ ១៩១៥ ហើយការរៀបចំក្រមអំពីឧក្រិដ្ឋកម្មនេះតាមអត្ថន័យនេះមានកំណើតដំបូងនៅឆ្នាំ ១៩៤៥ នៅសាលាក្តី Nuremberg[7]។

យោងតាមមាត្រា ៦(គ)នៃគោលការណ៍ Nuremberg

> “គ) ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ៖
>
> ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការនិរទេស និងអំពើអមនុស្សធម៌ផ្សេងៗទៀតដែលប្រព្រឹត្តឡើងមកលើជនស៊ីវិល ឬការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា នៅពេលដែលអំពើបែបនេះធ្វើឡើង ឬការធ្វើទុក្ខបុកម្នេញបែបនេះធ្វើឡើងនៅក្នុងការប្រព្រឹត្ត ឬពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព ឬឧក្រិដ្ឋកម្មសង្គ្រាម”។

ពាក្យពេចន៍ស្រដៀងគ្នានេះអាចរកឃើញមាននៅក្នុងលក្ខន្តិកៈតុលាការ ICTY។ លក្ខន្តិកៈតុលាការ ICTR និងលក្ខន្តិកៈទីក្រុងរ៉ូមតុលាការ ICC មិនបានរាប់បញ្ចូលលក្ខខណ្ឌតម្រូវត្រូវមានចំណងពាក់ព័ន្ធជាមួយនឹងជម្លោះប្រដាប់អាវុធឡើយ។

ដោយសារថា សេចក្តីជូនដំណឹងជាសាធារណៈដែលចេញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិរបស់ អ.វ.ត.ក បានកត់សម្គាល់ថា នៅក្នុងអំឡុងពេលសន្តិភាព ការចាត់ចំណាត់ថ្នាក់ទាហាន ជាយុទ្ធជន គឺមិនពាក់ព័ន្ធនឹងចំណាត់ថ្នាក់របស់ទាហានជាជនស៊ីវិល តាមមាត្រា ៥ ឡើយ ទើបបញ្ហាចោទសំខាន់អំពីលក្ខណៈទំនៀមទម្លាប់នៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ គឺទាក់ទងនឹងចំណាត់ថ្នាក់យុទ្ធជនរបស់ភាគីខ្លួនឯង ជាជនស៊ីវិល តាមគោលបំណងនៃ“ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ”នៅក្នុងបរិបទ ឬចំណងពាក់ព័ន្ធជាមួយនឹងជម្លោះប្រដាប់អាវុធ ដែលពួកគេមានឋានៈជាយុទ្ធជនយ៉ាងសកម្ម។

មូលហេតុដែលកំណត់និយមន័យ“ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ”នៅឆ្នាំ ១៩៤៥ គឺដើម្បីធ្វើឲ្យទៅជាបទឧក្រិដ្ឋចំពោះអំពើឃោរឃៅដែលមិនមានចែងនៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិ[8]។ ក្នុងករណីដែលឧក្រិដ្ឋ

[7] William A. Schabas *សេចក្តីណែនាំអំពីតុលាការព្រហ្មទណ្ឌអន្តរជាតិ* សារព័ត៌មានសាកលវិទ្យាល័យខេមប្រ៊ីជ ឆ្នាំ ២០១១ (បោះពុម្ពលើកទី ៤) ទំព័រ ១០៧។

[8] Cassese ជើងទំព័រ ៦ ខាងលើ ទំព័រ ៤៦៦។

កម្មពាក់ព័ន្ធនឹងនិយមន័យ"ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" បានប្រព្រឹត្តឡើងមកលើយុទ្ធជនរបស់ខ្លួនឯង ឧក្រិដ្ឋកម្មបែបនោះមិនមានចែងនៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិឡើយ។ ហេតុនេះ ហាក់ដូចជាមានសេចក្តីសន្និដ្ឋានមិនអាចចៀសរួចថា តាមរយៈការបញ្ចូលគ្នារវាងការបកស្រាយមុខងារលើពាក្យថា "ប្រជាជន ស៊ីវិល"ជាមួយនឹងការយល់ឃើញថា អំពើឃោរឃៅមកលើយុទ្ធជនរបស់ខ្លួនឯងមិនមានចែងនៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិ គឺថា ការហាមឃាត់"ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"មកលើយុទ្ធជនរបស់ខ្លួនឯងបានក្លាយជាផ្នែកមួយនៃវិធាននានានៅក្នុងច្បាប់ទម្លាប់អន្តរជាតិទាក់ទងនឹង"ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" ចាប់តាំងការហាមឃាត់នេះបានកើតឡើងនៅឆ្នាំ ១៩៤៥ មកម្លេះ ហើយនៅតែបន្តមាននៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ និងនៅតែបន្តមានដូច្នេះរហូតដល់សព្វថ្ងៃនេះ។